

# ផ្ទះកក់ក្ដៅ គ្រួសារសុខសាន្ដ

វគ្គ៖

# កិច្ចការដែលត្រូវធ្វើ មុនពេលសង់ផ្ទះ


ខ្ញុំស្រឡាញ់ម៉ូតផ្ទះដែលពុក
វាឯងកពុងកាន់ហ្នឹង
ឥឡូវរកម៉ូតផ្ទះ
និងថវិកាបានហើយយើងគួរ
ចាប់ផ្ដើមពីណាទៅមុនហ្ន៎?!


យើងរក
អ្នកម៉ៅការសិន
ដើម្បឲ្យគេដាក់តម្លៃ
មកថាអស់
ប៉ុន្មាន


យើងមិនធ្លាប់ធ្វើអីចឹង ធ្វើម៉េចដឹងថាជាង ណាល្អ?!
យើងអាចពិនិត្យមើលទឹកដៃ និងទំហំការងារដែលធ្លាប់ធ្វើពីមុន តើប្រហាក់ប្រហែលគម្រោងផ្ទះយើងទេ?
ចុះធ្វើម៉េចកុំឲ្យឈ្លោះគ្នា រឿងគុណភាពសម្ភារក្រោយពេលធ្វើហើយ?


យើងឲ្យជាងដាក់ ប្រភេទ សម្ភារមកឲ្យច្បាស់ ដូចជា ទំហំដែក ម៉ាកថ្នាំ ម៉ាកការ៉ូ ប្រភេទក្បឿង ឡាបូ បង្គន់..
សំខាន់ត្រូវមានកិច្ចសន្យាច្បាស់លាស់ និងមានការដឹងឮពីអាជ្ញាធរដែនដីកាន់តែល្អ


ចំណុចសំខាន់មួយទៀត គឺត្រូវសុំច្បាប់សាងសង់ពីសុរិយោដី ខណ្ឌ ស្រុក ក្រុង ឬខេត្ត ។ អាស្រ័យតាមផ្ទៃក្រឡាកម្រាលសំណង់ដែលត្រូវធ្វើ
ដាច់ខាតត្រូវតែដាក់ពាក្យស្នើសុំឬ? ពុកវា?!
វាជាកាតព្វកិច្ចចូលរួមការពារសុវត្ថិភាព និងសោភ័ណភាពតំបន់រស់នៅរបស់យើង

## ចំណុចគួរចងចាំ

- ស្វែងរកអ្នកម៉ៅការដែលផ្តោតលើគុណភាព និងទំនួលខុសត្រូវខ្ពស់ តាមរយៈការពិនិត្យមើល ប្រវត្តិអ្នកសាងសង់ កេរ្តិ៍ឈ្មោះ អាសយដ្ឋានក្រុមហ៊ុន ឬរស់នៅពិតប្រាកដ និងបទពិសោធន៍ដូចជាទំហំគម្រោងដែលគាត់ធ្វើ គ្រោះថ្នាក់ដែលកើតមាននៅក្នុងការដ្ឋានដែលកើតចេញពីភាពធ្វេសប្រហែលជាដើម ដោយធ្វើការសួរនាំអតិថិជនរបស់គាត់
- ផ្ទៀងផ្ទាត់តម្លៃ និងពិនិត្យមើលប្រភេទនៃសម្ភារដែលត្រូវប្រើប្រាស់ ជាមួយគម្រូប្លង់ស្ថាបត្យកម្ម ឲ្យបានត្រឹមត្រូវ ជៀសវាងមានបញ្ហានៅពេលនិងក្រោយសាងសង់ ។ព័ត៌មានកាន់តែលម្អិតនៅក្នុងបញ្ជីសម្ភារ និងតម្លៃកាន់តែល្អ ព្រោះផ្តល់ភាពងាយស្រួលក្នុងការប្រៀបធៀបពិចារណាថាគួរជ្រើសរើសយកអ្នកម៉ៅការមួយណា ។
- ធ្វើកិច្ចសន្យាឲ្យបានច្បាស់លាស់ដោយបញ្ជាក់ពីលក្ខខណ្ឌបង់ប្រាក់ រយៈពេលសាងសង់ ដោយមានភ្ជាប់សម្ភារដែលត្រូវប្រើ (អាចរកអ្នកដែលមានចំណេះក្នុងការធ្វើកិច្ចសន្យាពិនិត្យបន្ថែម)
- ស្នើសុំលិខិតអនុញ្ញាតិសាងសង់ពីអាជ្ញាធរដែលពាក់ព័ន្ធ (សូមអានបន្ថែម តាមការស្កេន QR នេះ:)



**ផ្ទះកក់ក្តៅ គ្រួសារសុខសាន្ត** ជាកម្រងរឿងខ្លីៗ ដែលនិយាយពីជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមួយស្ថិតក្នុងជីវភាពមធ្យម ។ នៅក្នុងវគ្គនីមួយៗនៃរឿងនេះ ត្រូវបានបញ្ចូលសារអប់រំខ្លីៗ ជូន ដល់អ្នកអាន ដើម្បីស្វែងយល់អំពីការគ្រប់គ្រង និងរៀបចំផែនការហិរញ្ញវត្ថុក្នុងគ្រួសារ ដំណើរការដាក់ស្នើកម្ចី ផលិតផលកម្ចី និងសារអប់រំផ្សេងទៀតទាក់ទងនឹងការប្រើប្រាស់កម្ចីប្រកបដោយប្រសិទ្ធភាព ។
យើងខ្ញុំស្វាគមន៍ទទួលយកគន្លឹះផ្សេងៗទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ តាមការស្នើរសុំពីប្រិយមិត្តដើម្បីបញ្ចូលទៅក្នុងសាច់រឿង ។
ដូច្នេះប្រសិនបើប្រិយមិត្តមាន គន្លឹះដែលល្អៗ អាចផ្ញើរមកកាន់ទំព័រ Facebook របស់
ហ្វឺស ហ្វាយនែន ឬតាមរយៈអ៊ីម៉ែល
infor@firstfiance.com.kh យើងខ្ញុំនឹងពិនិត្យ ហើយដាក់ជូន ប្រសិនបើយល់ឃើញថា អត្ថបទ ឬគន្លឹះនោះមានប្រយោជន៍ដល់ប្រិយមិត្តអ្នកអានផ្សេងទៀត ។

នាំមកជូនដោយ

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
## ហ្វឺស ហ្វាយនែន ភីអិលស៊ី

FIRST FINANCE

គេហទំព័រ ហ្វឺស ហ្វាយនែន
www.firstfinance.com.kh